ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៥៥ ប្រក.កសក.ប

# ប្រកាស
## ស្តីពី
## ការកែសម្រួលប្រការ៩ នៃប្រកាសលេខ១០៩ ប្រក.កសក.ប. ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាននិង មន្ទីរពិសោធន៍ជាតិកសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគមន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ច ឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ចំណុះអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនា-សម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយក-ដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញប្រកាសលេខ១០៩ ប្រក.កសក.ប ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាននិងមន្ទីរពិសោធន៍ជាតិកសិកម្ម ក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- បានឃើញប្រកាសលេខ៦០៩ ប្រក កញ្ញា ឆ្នាំ២០១៦ កសក ចុះថ្ងៃទី២៧.ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឲ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត
- យោងលិខិតលេខ១៣១១ មស.នក ចុះថ្ងៃច័ន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការមួយ.-**

ប្រការ៩ នៃប្រកាសលេខ១០៩ ប្រក.កសក.ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាននិងមន្ទីរពិសោធន៍ជាតិកសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្មត្រូវបានកែសម្រួល ដូចខាងក្រោម៖

**ប្រការ៩.- ថ្មី**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម មានការិយាល័យចំណុះចំនួន០៥ និងអង្គភាពចំណុះចំនួន០២ ដូចមានរាយឈ្មោះខាងក្រោម៖

១. ការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ
២. ការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស ផ្សព្វផ្សាយកសិកម្ម
៣. ការិយាល័យអប់រំ និងផ្សព្វផ្សាយកសិកម្ម
៤. ការិយាល័យប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម
៥. ការិយាល័យប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម
៦. មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងផ្សព្វផ្សាយកសិកម្មតាស្លាង(មានថ្នាក់ស្មើការិយាល័យរាជធានី-ខេត្ត)
៧. មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករគំរូនិងអភិវឌ្ឍន៍កសិករផ្សព្វផ្សាយកសិកម្មអង្គពពេល (មានថ្នាក់ស្មើការិយាល័យរាជធានី-ខេត្ត)

តួនាទី និងភារកិច្ចរបស់ការិយាល័យ និងអង្គភាពនីមួយៗ មានដូចខាងក្រោម៖

**៩.១ ការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖**

- សម្របសម្រួលរាល់សកម្មភាពការងាររដ្ឋបាល
- គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាល រាល់សកម្មភាពការងាររដ្ឋបាលនិងការងារសង្គម
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាលនិងការងារពិធីការ
- ផ្តល់ការផ្គត់ផ្គង់សម្ភារនិងការដឹកជញ្ជូន ដែលគាំទ្រដល់ប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន
- ការពារសន្តិសុខ សណ្តាប់ធ្នាប់និងអនាម័យក្នុងនាយកដ្ឋាន

- គ្រប់គ្រងសំណុំឯកសារជីវប្រវត្តិស្ថិតិក្របខ័ណ្ឌមន្ត្រីរាជការ
- សម្របសម្រួលរៀបចំបែបបទរដ្ឋបាលនិងឯកសារផ្សេងៗ សម្រាប់ការបណ្តុះបណ្តាលមន្ត្រី ឬទស្សនកិច្ចសិក្សាក្នុងនិងក្រៅប្រទេស
- រៀបចំឯកសារបៀវត្ស ប្រាក់កម្រៃ និងរបបឧបត្ថម្ភ ដោយសហការជាមួយនាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ
- លើកសំណើសុំការផ្ទេរសម្រួលភារកិច្ច ដំឡើងឋានៈ លើកសរសើរ ដាក់វិន័យ ឬកែសម្រួលរចនា-សម្ព័ន្ធតាមស្ថានភាពជាក់ស្តែង
- រៀបចំនិងកសាងគោលនយោបាយសម្រាប់ការងារផ្សព្វផ្សាយកសិកម្ម និងសម្របសម្រួលការងារកសាងផែនការ កម្មវិធី និងគម្រោងការងារប្រចាំឆ្នាំ
- ត្រួតពិនិត្យ វាយតម្លៃ សិក្សា និងធ្វើអង្កេតកេឲ្យឃើញឥទ្ធិពល នៃសកម្មភាពផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍប្រភពធនធាន ការអនុវត្តផែនការ គោលនយោបាយ និងកំណត់អាទិភាពវិធីសាស្ត្រមានប្រសិទ្ធភាពនៅក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
- ធ្វើទំនាក់ទំនង សម្របសម្រួល ផ្លាស់ប្តូរព័ត៌មាន ការងារសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍នានា លើការងារផ្សព្វផ្សាយកសិកម្ម
- ធ្វើរបាយការណ៍ទូទាត់ថវិកាចំណូល ចំណាយក្នុងការអនុវត្តថវិការដ្ឋ និងគម្រោងផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំនិងគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ បញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិ និងសម្ភារបរិក្ខាររបស់នាយកដ្ឋាន
- គ្រប់គ្រងសន្និធិនិងបែងចែកសម្ភារ បរិក្ខារ ប្រេងឥន្ធនៈ របស់នាយកដ្ឋាន
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់នាយកដ្ឋាន ដោយធ្វើការបូកសរុបរបាយការណ៍និងការងារផ្សេងៗពីបណ្តាការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឲ្យ។

៩.២-ការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស ផ្សព្វផ្សាយកសិកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងសម្របសម្រួលលើការវាយតម្លៃតម្រូវការបណ្តុះបណ្តាលរបស់មន្ត្រីផ្សព្វផ្សាយកសិកម្ម
- រៀបចំបង្កើត វិភាគ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យ មន្ត្រីផ្សព្វផ្សាយកសិកម្ម ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករគំរូ កសិករឆ្នើម កសិករគ្រូ និងកសិករផ្សព្វផ្សាយកសិកម្ម
- គ្រោង និងសម្របសម្រួលអនុវត្តកម្មវិធីបណ្តុះបណ្តាលសមស្របផ្នែកបច្ចេកទេសផ្សព្វផ្សាយដល់មន្ត្រី ផ្សព្វផ្សាយកសិកម្ម រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើផលប៉ះពាល់ការបណ្តុះបណ្តាលរបស់មន្ត្រីផ្សព្វផ្សាយកសិកម្ម
- សហការជាមួយអង្គភាពជំនាញ និងអង្គភាពអប់រំក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិស័យឯកជន ដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំអនុវត្តស្តង់ដារគុណភាពបណ្តុះបណ្តាលសម្រាប់ការងារផ្សព្វផ្សាយកសិកម្ម
- ផ្តល់យោបល់ និងជំនួយផ្នែកបច្ចេកទេសផ្សព្វផ្សាយកសិកម្ម ដល់បុគ្គលិកពាក់ព័ន្ធថ្នាក់ជាតិ និងរាជធានីខេត្ត

- រៀបចំបង្កើត និងអនុវត្តបណ្តាញគោលការណ៍ណែនាំ ការងារយេនឌ័រ និងការអភិវឌ្ឍក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
- សិក្សាពីស្ថានភាព និងតម្រូវការអាហារូបត្ថម្ភរបស់គ្រួសារកសិករ
- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសក្នុងការទទួលស្គាល់ និងកំណត់លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសកសិករផ្សព្វផ្សាយកសិកម្ម
- ចងក្រង និងរៀបចំក្រុមកសិករគំរូ កសិករឆ្នើម កសិករគ្រូ សម្រាប់បណ្តុះបណ្តាល និងបំពាក់បំប៉នឱ្យក្លាយជាកសិករផ្សព្វផ្សាយកសិកម្ម
- សម្របសម្រួល លើកទឹកចិត្ត និងគាំទ្របច្ចេកទេសកសិកម្មសមស្របដល់កសិករផ្សព្វផ្សាយកសិកម្ម
- សម្របសម្រួល និងជំរុញឱ្យមានមជ្ឈមណ្ឌលសិក្សាសហគមន៍
- រៀបចំកសាងគម្រោង កម្មវិធី និងសហការជាមួយ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍នានា ដើម្បីទទួលបានការចូលរួម និងគាំទ្រដល់កសិករផ្សព្វផ្សាយកសិកម្ម
- រៀបចំកសាងផែនការ ការងាររយៈពេលខ្លី មធ្យម និងរយៈពេលវែង របស់ការិយាល័យ
- សរុបរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងទៀតៗដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ។

៩.៣ ការិយាល័យអប់រំ និងផ្សព្វផ្សាយកសិកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផលិតឯកសារផ្សព្វផ្សាយតាមប្រព័ន្ធសាធារណៈនិងផ្តល់រាល់ឯកសារស្រាវជ្រាវនិងលទ្ធផលពិសោធន៍លើវិស័យកសិកម្ម ដើម្បីជូនពេងពុម្ព
- ដឹកនាំការធ្វើបង្ហាញផ្សព្វផ្សាយអំពីប្រភេទ បរិមាណ និងគុណភាពផលិតផលកសិកម្មដល់សាធារណជនក្រោមរូបភាពជាពិព័រណ៍ ផ្សារណាត់ផលិតផលកសិកម្ម ដើម្បីទាក់ទាញនិងបង្កើនទីផ្សារ
- តាមដានការអនុវត្តនិងការវាយតម្លៃលទ្ធផលការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម សកម្មភាព និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម និងលើកវិធានការកែលម្អជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ពង្រឹងសមត្ថភាពការិយាល័យផ្សព្វផ្សាយកសិកម្មថ្នាក់រាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក និងសេវាកម្មផ្សព្វផ្សាយព័ត៌មាន
- គ្រប់គ្រងបណ្ណាល័យនិងឯកសារបច្ចេកទេសកសិកម្ម
- សិក្សាស្រាវជ្រាវប្រមូលផ្តុំឯកសារបច្ចេកទេសកសិកម្ម ដោយសហការជាមួយអង្គភាពជំនាញនានា អង្គការជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរាជរដ្ឋាភិបាលដើម្បីរៀបចំអត្ថបទចងក្រងទស្សនាវដ្តី កាសែតកសិកម្ម ព្រឹត្តិបត្រ គំនូររូបភាព កំណាព្យ រឿងនិទានខ្លីៗ
- បោះពុម្ពរាល់ឯកសារស្រាវជ្រាវនិងលទ្ធផលបានពីបទពិសោធន៍លើវិស័យកសិកម្មនានា និងរាល់សមិទ្ធផលដែលមានភាពជោគជ័យ ដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅគ្រប់មជ្ឈដ្ឋាន
- គ្រប់គ្រងពេងពុម្ពនិងឯកសារបច្ចេកទេសកសិកម្មដែលបោះពុម្ពរួច សម្រាប់ការសិក្សារបស់និស្សិតនិងកសិករជឿនលឿនទូទាំងប្រទេសយកទៅអនុវត្ត
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឲ្យ។

៩.៤ ការិយាល័យប្រព័ន្ធកសិកម្មនិងសេដ្ឋកិច្ចកសិកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលថ្មីស្តីបច្ចេកទេស លើការវិភាគប្រព័ន្ធកសិកម្ម
- បង្កើត អនុវត្ត និងគ្រប់គ្រងប្រព័ន្ធព័ត៌មានកសិកម្ម ដោយបញ្ចូលនូវទិន្នន័យដែលពាក់ព័ន្ធនឹងបទដ្ឋានអនុវត្តបច្ចេកវិទ្យា ដែលសមស្របទៅនឹងភូមិសាស្ត្រជាក់ស្តែងនីមួយៗ
- សម្របសម្រួលនិងជួយគាំទ្រដល់ការវិភាគប្រព័ន្ធកៀគ្របរិស្ថាន និងផ្សព្វផ្សាយបន្តនូវបទដ្ឋានអនុវត្តបច្ចេកវិទ្យាដល់រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ
- ថែរក្សា និងកែសម្រួលនូវទិន្នន័យនៃប្រព័ន្ធព័ត៌មានកសិកម្ម
- សម្របសម្រួលដល់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវទិន្នន័យគ្រឹះប្រព័ន្ធកសិកម្ម សម្រាប់ធ្វើផែនការផ្សព្វផ្សាយកសិកម្ម
- រៀបចំនិងកសាងការអនុវត្តបច្ចេកវិទ្យានិងអភិវឌ្ឍដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ
- ចូលរួមសកម្មភាពអន្តរាគមន៍សង្គ្រោះដំណាំនិងស្តារការខូចខាតដំណាំបង្កដោយគ្រោះធម្មជាតិឬការរាតត្បាតពីសមាសភាពចង្រៃ
- សិក្សាស្រាវជ្រាវនិងវិភាគសេដ្ឋកិច្ចសង្គមរបស់ប្រជាកសិករ
- សិក្សាស្រាវជ្រាវពីតម្រូវការនិងស្ថានភាពទីផ្សារ និងផ្សព្វផ្សាយព័ត៌មានដល់មូលដ្ឋានភូមិ ឃុំ
- សិក្សា វិភាគសក្តានុពលភាពសេដ្ឋកិច្ចកសិដ្ឋាន និងស្រែចម្ការរបស់ប្រជាកសិករ
- សម្របសម្រួលធ្វើកិច្ចសន្យាផលិតកម្មកសិកម្មជាមួយផលិតករ កសិករ និងសេវាជនបទ
- សិក្សាពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃបច្ចេកវិទ្យាព័ត៌មានកសិកម្មនៅមូលដ្ឋានជាក់ស្តែងនីមួយៗ
- សិក្សាខ្សែសង្វាក់ផលិតកម្មរបស់ទីផ្សារជូនប្រជាកសិករតាមភូមិសាស្ត្រ
- រៀបចំគោលនយោបាយសេដ្ឋកិច្ចទីផ្សារលើពិពិធកម្មកសិកម្មនិងផលិតភាពកសិកម្ម
- ធ្វើការសិក្សាលម្អិតផ្នែកសេដ្ឋកិច្ច ដើម្បីពង្រឹងសមត្ថភាពបច្ចេកទេសនៃប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឲ្យ។

៩.៥- ការិយាល័យប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ ទាក់ទងទៅនឹងប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម
- ប្រមូលចងក្រង និងកត់ត្រាជាប្រចាំ រាល់លិខិតបទដ្ឋាន ឯកសារព្រឹត្តិបត្រ និងអត្ថបទបច្ចេកទេសកសិកម្មនានាអំពីលទ្ធផលស្រាវជ្រាវរកឃើញថ្មីៗនៅក្នុងនិងក្រៅប្រទេស
- បណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយកសិកម្ម ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករគំរូ កសិករឆ្នើម កសិករគ្រូ និងកសិករផ្សព្វផ្សាយកសិកម្ម ពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាកសិកម្ម
- ប្រមូល ចងក្រង និងរៀបចំបណ្តាញព័ត៌មានកសិកម្មតាមតម្រូវការទីផ្សារក្នុងស្រុក និងក្នុងតំបន់
- សម្របសម្រួល និងសហការជាមួយអង្គភាពជំនាញ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍នានាពាក់ព័ន្ធនឹងវិស័យកសិកម្មចូលរួមគាំទ្រ បង្កើតប្រព័ន្ធបច្ចេកវិទ្យាកសិកម្ម ទទួលបាន និងប្រើប្រាស់ព័ត៌មានកសិកម្មដើម្បីបង្កើនប្រសិទ្ធភាពសេវាផ្សព្វផ្សាយកសិកម្មដល់អ្នកពាក់ព័ន្ធ
- ផ្សព្វផ្សាយព័ត៌មានបច្ចេកទេសកសិកម្ម និងព័ត៌មានទីផ្សារតាមប្រព័ន្ធព័ត៌មានវិទ្យា

- តាមដាន វាយតម្លៃ និងធ្វើបច្ចុប្បន្នភាព ប្រព័ន្ធព័ត៌មានវិទ្យាកសិកម្ម ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ព័ត៌មានឆាប់រហ័ស និងចាំបាច់នៅតាមមូលដ្ឋាន
- រៀបចំ និងគ្រប់គ្រងបណ្ណាល័យអេឡិចត្រូនិច បណ្តាញទំនាក់ទំនងសង្គម គេហទំព័រព័ត៌មានផ្សព្វផ្សាយកសិកម្ម និងជួយគាំទ្រដល់ដំណើរការរបស់បណ្តុំអ្នកចូលរួមចែករំលែកសម្ភារ ឯកសារ និងសេវាផ្សព្វផ្សាយកសិកម្ម
- រៀបចំ និងដំណើរការប្រព័ន្ធទទួល និងឆ្លើយតបព័ត៌មានរហ័ស
- រៀបចំកសាងផែនការការងាររយៈពេលខ្លី មធ្យម និងរយៈពេលវែងរបស់ការិយាល័យ
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ការិយាល័យ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ។

៩.៦ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មតាស្លាង មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- កសាងគម្រោងផែនការ សកម្មភាពក្នុងការអភិវឌ្ឍដំណាំស្រូវ ដំណាំបន្លែ ដំណាំហូបផ្លែ ការចិញ្ចឹមត្រី ការចិញ្ចឹមសត្វ និងអភិវឌ្ឍប្រព័ន្ធកសិកម្មចម្រុះ
- សហការសម្របសម្រួលវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំគ្រប់ប្រភេទនិងការដាំដុះតាមលក្ខណៈវិទ្យាសាស្ត្រ ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារក្នុងនិងក្រៅស្រុក
- ផ្សព្វផ្សាយបច្ចេកទេសកសិកម្មនិងបទពិសោធន៍ដែលរកឃើញថ្មីជូនដល់កសិករ អង្គការកសិករ សហគមន៍អភិវឌ្ឍកសិកម្ម តាមរយៈការធ្វើបង្ហាញ រៀបចំទិវាស្រែ និងធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍រវាងកសិករនិងកសិករគំរូ រវាងអង្គការដៃគូអភិវឌ្ឍន៍នានា ក្នុង និងក្រៅតំបន់គោលដៅ
- គ្រប់គ្រងនិងថែរក្សា ចលនទ្រព្យនិងអចលនទ្រព្យរបស់មជ្ឈមណ្ឌល
- សហការជាមួយអង្គភាពជំនាញនានា ក្នុងការសាកល្បងនិងបន្សាំដំណាំគ្រប់ប្រភេទ
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់មជ្ឈមណ្ឌល
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឲ្យ។

៩.៧-មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករគំរូនិងអភិវឌ្ឍន៍កសិករផ្សព្វផ្សាយកសិកម្មអង្គពពេល មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- កសាងគម្រោងផែនការ និងសកម្មភាព ជំរុញការអនុវត្តកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស ផ្នែកផ្សព្វផ្សាយកសិកម្មថ្នាក់ខេត្ត រាជធានី ស្រុក ខណ្ឌ និងកសិករ
- សហការសម្របសម្រួលការបណ្តុះបណ្តាលបំពាក់បំប៉នមន្ត្រីផ្សព្វផ្សាយ អង្គការកសិករ សហគមន៍អភិវឌ្ឍកសិកម្ម ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងកសិករ
- សហការចូលរួមសម្របសម្រួល ការស្រាវជ្រាវ ពិសោធន៍បន្សាំ ដំណាំគ្រប់ប្រភេទ ការចិញ្ចឹមសត្វ វារីវប្បកម្ម ផ្លាស់ប្តូរបទពិសោធន៍រវាងកសិករ និងកសិករគំរូ រវាងអង្គការកសិករ សហគមន៍អភិវឌ្ឍកសិកម្ម
- សម្របសម្រួល ដឹកនាំ និងផ្សព្វផ្សាយការអនុវត្តបច្ចេកវិទ្យាកសិកម្មវៃឆ្លាត
- គ្រប់គ្រង និងថែរក្សា ចលនទ្រព្យ និងអចលនទ្រព្យរបស់មជ្ឈមណ្ឌល
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់មជ្ឈមណ្ឌល
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ។

**ប្រការ៣.-**

ក្រៅពីការកែសម្រួលប្រការ៩ ខ្លឹមសារទាំងឡាយនៃប្រកាសលេខ១០៩ ប្រក.កសក.ប ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន និងមន្ទីរពិសោធន៍ជាតិកសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម ត្រូវរក្សាទុកជាធរមានដដែល។

**ប្រការ៤.-**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែ ប.សាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ឧបសម្ព័ន្ធនៃប្រកាសលេខ..២៥៥.......ប្រក.កសក.ប ចុះថ្ងៃ..ព្រហ...១៤រោច.ខែ..ពិសាខ...ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ត្រូវនឹង ថ្ងៃទី..១៤........ខែ..មិថុនា.......ឆ្នាំ២០១៨

## អង្គការលេខរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម

ថ្នាក់ដឹកនាំនាយកដ្ឋាន

- ៩.១ ការិយាល័យ រដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ
- ៩.២ ការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស ផ្សព្វផ្សាយកសិកម្ម
- ៩.៣ ការិយាល័យអប់រំនិងផ្សព្វផ្សាយកសិកម្ម
- ៩.៤ ការិយាល័យប្រព័ន្ធកសិកម្មនិងសេដ្ឋកិច្ចកសិកម្ម
- ៩.៥ ការិយាល័យប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម
- ៩.៦ មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងផ្សព្វផ្សាយកសិកម្មតាស្អាង
- ៩.៧ មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិករគំរូ និងអភិវឌ្ឍន៍កសិករផ្សព្វផ្សាយកសិកម្មអង្គពពេល